## តើយើងអាចប្រើកម្លាំងឆ្លើយតបកម្រិតណា ដើម្បីការពារទ្រព្យសម្បត្តិ និងកុំឲ្យរងទោសដោយសារទង្វើខ្លួនឯង?

## មាត្រា ៣៣ ការការពារស្របច្បាប់ (ក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩)

*បុគ្គលណាដែលប្រព្រឹត្តបទល្មើសក្នុងសភាពការពារស្របច្បាប់ មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។ ការការពារស្របច្បាប់ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ ៖ - បទល្មើសត្រូវចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិប្រឈមមុខនឹង<u>ការល្មើសបំពានមួយដែលមិនត្រឹមត្រូវ</u> - បទល្មើស និងការល្មើសបំពាន ត្រូវតែកើតឡើងក្នុង<u>ពេលជាមួយគ្នា និង</u> - គ្មានវិសមាមាត្រ រវាងមធ្យោបាយការពារ ដែលប្រើប្រាស់ និងទម្ងន់នៃការល្មើសបំពាន ។*

**១.** វាការឆ្លើយតបនឹងអំពើវាយប្រហារខុសច្បាប់ ដូចជា ចោរឆក់ ក៏ប៉ុន្តែ ការអនុវត្តសាលក្រមដោយអាជ្ញាធរ មិនមែនទង្វើខុសច្បាប់ ដែលយើងអាចតបតថាជាទង្វើការពារខ្លួនឬទ្រព្យសម្បត្តិទេ។ ការវាយតប ត្រូវធ្វើភ្លាមៗ។ ប្រសិនមិនដូចនេះទេ វាអាចថាជាការសងសឹក នឹងមិនអាចលើកថាជាការការពារខ្លួនទេ។ ការវាយតប ត្រូវតែចាំបាច់ និងសមមាត្រា ។ ឧទាហរណ៍ ការគ្រាន់តែដើម្បីបានកាបូបមួយដែលត្រូវបានគេឆក់ យកមកវិញ យើងបើកឡានបុកចោរឆក់ ឬត្រឹមតែការពារផ្លែបោមមួយ វាយគេដល់ស្លាប់ នោះមិនមែនសមមាត្រទេ។

**២.** ឧទាហរណ៍មួយទៀត ដើម្បីការពារចោរលួចបេះស្វាយ យើងដាក់ខ្សែភ្លើងមានចរន្តអគ្គិសនីព័ទ្ធជុំវិញចំការ។ វាមិនមែនជាការពារស្របច្បាប់ទេ។ ទី១. ដោយសារមិនទាន់ការវាយប្រហារ។ ទី២. វិធានការនេះ បង្កផលវិបាកលើសជ្រុលពីអ្វីដែលយើងចង់បាន ហើយដែលអាចសម្លាប់មនុស្សស្លូតត្រង់។

**៣.** តើមានអ្វីកើតឡើង ប្រសិនបើយើងប្រើកម្លាំងជ្រុល ហើយតើមានទោសទណ្ឌដែរឬទេ? បុគ្គល ដែលបានប្រព្រឹត្តតប នឹងទទួលខុសត្រូវចំពោះទង្វើខ្លួនដែលបានធ្វើជ្រុល។ ក៏ប៉ុន្តែ គាត់អាចទទួលខុសត្រូវលើបទល្មើសស្រាលជាង។ ឧទារណ៍ ជំនួសឲ្យការចោទប្រកាន់នូវបទល្មើសបង្ករបួសស្នាមដោយចេតនា ការចោទប្រកាន់ពីបទបង្ករបួសស្នាមដោយអចេតនា អាចត្រូវបានធ្វើឡើង។ បន្ថែមពីលើនេះ គាត់អាចនឹងទទួលបានស្ថានសម្រាល ដោយសារគាត់ការពារទ្រព្យ និងធ្វើឡើងក្នុងស្ថានភាពច្របូកច្របល់ ដែលអាចនាំឲ្យការសម្រេចចិត្ត មិនបានត្រឹមត្រូវ។

**៤.** ជាសរុប អស់លោកអ្នកមានសិទ្ធិការពារទ្រព្យ ឬអាយុជីវិត ក៏ប៉ុន្តែ អ្នកត្រូវគោរពតាមលក្ខខណ្ឌមានចែងក្នុងច្បាប់កំណត់។ ប្រសិនបើមិនដូចនេះទេ ម្ចាស់ទ្រព្យ អាចក្លាយជាជនល្មើស និងទទួលខុសត្រូវ។ នេះជាច្បាប់ ហើយ ការអះអាងថា មិនបានដឹងច្បាប់ មិនមែនជាការដោះសារអាចទទួលយកបានទេ។

នេះហើយជា មូលហេតុ ដែលខ្ញុំបានធ្វើជាវីដេអូនេះ។ វាជួយជាគំនិត ហើយការសម្រេចយ៉ាងណា គឺនឹងត្រូវធ្វើឡើងដោយតុលាការ អាស្រ័យទៅតាមអង្គហេតុនៃសំណុំរឿងជាក់ស្តែងនីមួយៗ។ សូមអរគុណ!